# EMERGENCY BROADBAND BENEFIT

## ត្រូវការជំនួយចំពោះតម្លៃអ៊ីនធឺណិតមែនទេ?

EMERGENCY BROADBAND BENEFIT

**ជំហាន 1** តើខ្ញុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែរឬទេ?

ចូលទៅគេហទំព័រ **GetEmergencyBroadband.org/do-i-qualify/** ឬទូរសព្ទទៅលេខ **833-511-0311** ដើម្បីរកមើលថាតើអ្នកមានសិទ្ធិទទួលបានដែរឬទេ។



**ជំហាន 2** ប្រសិនបើអ្នកមានលក្ខណសម្បត្តិគ្រប់គ្រាន់ តើអ្វីដែលពណ៌នាអំពីស្ថានភាពរបស់អ្នកបានល្អបំផុត?

### ខ្ញុំមិនមានសេវាកម្មអ៊ីនធឺណិតទេ។

- ពិនិត្យមើលថា តើអ្នកមានលក្ខណសម្បត្តិគ្រប់គ្រប់ដែរឬទេដោយការទូរសព្ទទៅលេខ **833-511-0311**។
- ដាក់ពាក្យសុំតាមរយៈ **National Verifier (អ្នកផ្ទៀងផ្ទាត់ថ្នាក់ជាតិ)** ហើយបន្ទាប់មកជ្រើសរើសអ្នកផ្តល់សេវាអ៊ីនធឺណិតដែលចូលរួម។
- ដាក់ពាក្យសុំតាមរយៈអ្នកផ្តល់សេវាអ៊ីនធឺណិតដែលចូលរួម។

### ខ្ញុំមានសេវាកម្មអ៊ីនធឺណិតចំណូលទាប។

- ទូរសព្ទ ឬទាក់ទងតាមអ៊ីនធឺណិតទៅអ្នកផ្តល់សេវាអ៊ីនធឺណិតរបស់អ្នក។ ស្នើសុំ ឬស្វែងរកអត្ថប្រយោជន៍អ៊ីនធឺណិតនៅពេលមានអាសន្ន (Emergency Broadband Benefits, EBB)
- ប្រសិនបើអ្នកប្រើប្រាស់ការបញ្ចុះតម្លៃសម្រាប់សេវាកម្មល្បឿនលឿន និងបង់ថ្លៃ អ្នកត្រូវតែ "ចូលរួម" ដើម្បីទទួលអ៊ីណិតតម្លៃទាបរបស់អ្នក នៅពេលដែល EBB បញ្ចប់។
- ជម្រើសមួយផ្សេងទៀតគឺ ដាក់ពាក្យស្នើសុំអត្ថប្រយោជន៍អ៊ីនធឺណិតនៅពេលមានអាសន្នតាមរយៈ **National Verifier (អ្នកផ្ទៀងផ្ទាត់ថ្នាក់ជាតិ)** ហើយទទួលសេវាកម្មបន្ថែមពីអ្នកផ្តល់សេវាមួយផ្សេងទៀត។

### ខ្ញុំមានសេវាកម្មអ៊ីនធឺណិតប៉ុន្តែវាមិនមែនជាផ្នែកនៃកម្មវិធីចំណូលទាបទេ។

- សាកសួរអ្នកផ្តល់សេវាអ៊ីនធឺណិតរបស់អ្នក ដើម្បីរកមើលថាតើអ្នកអាចដាក់ពាក្យសុំការបញ្ចុះតម្លៃចំពោះសេវាកម្មបច្ចុប្បន្នរបស់អ្នក ឬថាតើអ្នកអាចជ្រើសរើសកម្រិតសេវាកម្មអ៊ីនធឺណិតផ្សេង ហើយអនុវត្តការបញ្ចុះតម្លៃបានដែរឬទេ។

### ខ្ញុំមានសេវាកម្មអ៊ីនធឺណិត ប៉ុន្តែ ចង់ផ្លាស់ប្តូរសេវាកម្មរបស់ខ្ញុំ។

- អ្នកអាចប្រើប្រាស់អត្ថប្រយោជន៍អ៊ីនធឺណិតនៅពេលមានអាសន្ន ដើម្បីទទួលបានសេវាកម្មចល័តឬបន្ថែមសេវាកម្មអ៊ីនធឺណិតមួយផ្សេងទៀតសម្រាប់គ្រួសាររបស់អ្នក។ (គ្រួសារមួយអាចនឹងទទួលបានការបញ្ចុះតម្លៃតែមួយប៉ុណ្ណោះ។)
- ដាក់ពាក្យសុំនៅគេហទំព័រ **GetEmergencyBroadband.org** បន្ទាប់មកជ្រើសរើសអ្នកផ្តល់សេវាអ៊ីនធឺណិត នៅពេលដែលត្រូវបានអនុញ្ញាត។

### ខ្ញុំមានគណនីដែលឧបត្ថម្ភដោយសាលារៀន។

- សាកសួរសាលារៀនរបស់អ្នក ដើម្បីរកមើលថាតើគណនីដែលត្រូវបានឧបត្ថម្ភបញ្ចប់នៅពេលណា។ ជម្រើសរបស់អ្នករួមមាន៖
  - សួរអ្នកផ្តល់សេវាអ៊ីនធឺណិតបច្ចុប្បន្នថាតើអ្នកអាចបន្តនៅក្នុង ឬចុះឈ្មោះក្នុងកម្មវិធីអ៊ីនធឺណិតចំណូលទាប ហើយប្រើប្រាស់ការបញ្ចុះតម្លៃរបស់អត្ថប្រយោជន៍អ៊ីនធឺណិតនៅពេលមានអាសន្នបានដែរឬទេ។
  - ទទួលបានអ៊ីនធឺណិតពីអ្នកផ្តល់សេវាអ៊ីនធឺណិតថ្មី ហើយដាក់ពាក្យសុំ EBB ជាបណ្តោះអាសន្ន។ ពិចារណាលើអ្នកផ្តល់សេវាអ៊ីនធឺណិតដែលមានកម្មវិធីអ៊ីនធឺណិតចំណូលទាបដែលអាចចំណាយបាន និងកំពុងបន្ត។

### ខ្ញុំមានសេវាកម្ម Lifeline។

- អ្នកមានសិទ្ធិទទួលបានដោយស្វ័យប្រវត្តិ ប៉ុន្តែត្រូវចុះឈ្មោះដើម្បីប្រើប្រាស់ការបញ្ចុះតម្លៃរបស់អត្ថប្រយោជន៍អ៊ីនធឺណិតនៅពេលមានអាសន្ន។
- អ្នកអាចរក្សាទុកអ្នកផ្តល់សេវាដដែលបាន។ អ្នកអាចដាក់ពាក្យសុំការឧបត្ថម្ភចំពោះកម្រិតសេវាកម្មអ៊ីនធឺណិតបច្ចុប្បន្នរបស់អ្នក ឬបង្កើនកម្រិតខណៈពេលមានអត្ថប្រយោជន៍អ៊ីនធឺណិតនៅពេលមានអាសន្នបាន។
- អ្នកអាចឱ្យអ្នកផ្តល់សេវាអ៊ីនធឺណិតថ្មីផ្តល់ជូននូវសេវាកម្ម និងអនុវត្តការបញ្ចុះតម្លៃទៅសេវាកម្មថ្មីបាន។

### ខ្ញុំរស់នៅលើដីកុលសម្ព័ន្ធ។

- ប្រសិនបើអ្នករស់នៅលើដីកុលសម្ព័ន្ធ ហើយត្រូវតាមលក្ខខណ្ឌតម្រូវនៃសិទ្ធិទទួលបានផ្សេងទៀត អ្នកអាចទទួលការបញ្ចុះតម្លៃប្រចាំខែសរុបរហូតដល់ទៅ $75 ព្រមទាំងការបញ្ចុះតម្លៃលើឧបករណ៍។
- **ចូលទៅគេហទំព័រស្តីពីអត្ថប្រយោជន៍កុលសម្ព័ន្ធ** ដើម្បីស្វែងយល់បន្ថែម

**ចុចសម្រាប់ព័ត៌មានបន្ថែម៖** **អ្នកផ្តល់សេវាអ៊ីនធឺណិតរបស់ EBB ប្រចាំរដ្ឋ WASHINGTON**

King County

Seattle

KC DCE: 11553w